**UNITED NATIONS**
CAMBODIA OFFICE OF THE
HIGH COMMISSIONER FOR HUMAN RIGHTS

**NATIONS UNIES**
BUREAU DU HAUT COMMISSAIRE
AUX DROITS DE L'HOMME AU CAMBODGE

Special Representative of the Secretary-General
for Human Rights in Cambodia
តំណាងពិសេសរបស់លោកអគ្គលេខាធិការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

OHCHR

# សារលិខិតរបស់តំណាងពិសេសរបស់លោកអគ្គលេខាធិការអង្គការ សហប្រជាជាតិ ផ្ញើជូនប្រជាជនកម្ពុជា ក្នុងទិវាសិទ្ធិមនុស្សអន្តរជាតិ

១- ឆ្នាំក្រោយនៅថ្ងៃនេះដែរ គឺជាទិវាបុណ្យខួបលើកទី៦០ នៃការអនុម័តសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ។ សេចក្តីប្រកាសនេះមានលក្ខណៈជាសកលសុទ្ធសាធនៅក្នុងបទដ្ឋាន និងគោលដៅរបស់វា ហើយវាគឺជាមូលដ្ឋានគ្រឹះមួយសំរាប់ច្បាប់ គោលនយោបាយនានា និងការអនុវត្តន៍របស់រដ្ឋ ។ សេចក្តីប្រកាសនេះ ត្រូវបានរៀបចំ និងអនុម័ត ដោយឆ្លើយតបទៅនឹងអំពើព្រៃផ្សៃសាហាវយង់ឃ្នងទាំងឡាយ ដែលកើតមាននៅមុន និងនៅក្នុងសង្គ្រាមលោកលើកទីពីរ ។ សេចក្តីប្រកាសជាសកលនេះ បង្កើតនូវទំនាក់ទំនងយ៉ាងច្បាស់មួយ រវាងការរំលោភលើសិទ្ធិមនុស្សជាមូលដ្ឋាន និងជំលោះជាតិនិងអន្តរជាតិ ។ បុព្វកថានៃសេចក្តីប្រកាសនេះ ចែងថា " ការមិនទទួលស្គាល់ និងការប្រមាថមើលងាយសិទ្ធិមនុស្ស បាននាំទៅកាន់អំពើព្រៃផ្សៃសាហាវយង់ឃ្នង ធ្វើឱ្យក្តៅក្រហាយដល់សតិសម្បជញ្ញៈមនុស្សជាតិ " ។ ទន្ទឹមនឹងនេះដែរ បុព្វកថានេះ ប្រកាសអំពី " ការកើតឡើងនូវពិភពលោកមួយដែលមនុស្សជាតិត្រូវមានសេរីភាពក្នុងការនិយាយស្តី និងជំនឿរួចផុតពីភាពភ័យខ្លាច និងទុគ៌តភាព " គឺជា " សេចក្តីប្រាថ្នាដ៏ខ្ពស់បំផុតរបស់មនុស្សទូទៅ " ។ សេចក្តីប្រកាសជាសកលនេះ ត្រូវបានអនុម័តជាឯកច្ឆ័នដោយមហាសន្និបាតអង្គការសហប្រជាជាតិ គឺជាមូលដ្ឋានគ្រឹះសំរាប់ការបង្កើត និងការអនុម័តអនុសញ្ញា និងសន្ធិសញ្ញានានាស្តីពីសិទ្ធិមនុស្ស ។ សន្ធិសញ្ញាទាំងនោះ រួមមាន កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ អនុសញ្ញា និងសេចក្តីប្រកាសនានា ដើម្បីការពារសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់ស្ត្រី កុមារ ជនជាតិដើមភាគតិច ជនជាតិភាគតិច និងជនពិការ និងការហាមឃាត់ដាច់ខាតចំពោះទោសកម្ម ការធ្វើទារុណកម្ម និងរូបភាពដទៃទៀតនៃការបន្ថោកបន្ទាប ។

២- ឫសគល់ និងគោលបំណងនៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ទាក់ទងជាពិសេសចំពោះកម្ពុជានាពេលបច្ចុប្បន្ននេះ ។ ការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរបំផុតដោយរបបខ្មែរក្រហម បាននាំឱ្យប្រជាជនរបស់ខ្លួនរងការឈឺចាប់មិនអាចពណ៌នាបាន ហើយមានមនុស្សជាងមួយលាននាក់ត្រូវបាត់បង់ជីវិត ។ សង្គ្រាមនេះបានបំផ្លិចបំផ្លាញសេដ្ឋកិច្ច អង្គការសង្គម និងមរតកវប្បធម៌របស់ប្រជាជន ។ សង្គ្រាមនេះបាននាំឱ្យមានអន្តរាគមន៍ពីរដ្ឋឯទៀតក្នុងកិច្ចការរបស់ខ្លួន ។ ហើយជាយថាហេតុ អង្គការសហប្រជាជាតិ បានជួយរៀបចំបង្កើតឱ្យមានឡើងវិញនូវច្បាប់ សណ្តាប់ធ្នាប់និងសន្តិសុខរបស់ប្រជាជន តាមរយៈការប្រកាសអំពីសិទ្ធិមនុស្សជាបទដ្ឋានគ្រឹះរបស់កម្ពុជា ។

#10, Street 302, Sangkat Boeng Keng Kang I, Khan Chamcar Mon, Phnom Penh, Cambodia.
Tel: (855) 23 987 671 / 987 672 / 993 590 / 993 591 or 216 342 Fax: (855) 23 212 579 or 213 587 E-mail: cambodia@ohchr.org

នូវច្បាប់ សណ្តាប់ធ្នាប់និងសន្តិសុខរបស់ប្រជាជន តាមរយៈការប្រកាសអំពីសិទ្ធិមនុស្សជាបទដ្ឋានគ្រឹះរបស់កម្ពុជា ។ សន្ធិសញ្ញានានាបានអនុលោមតាមសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ដែលបច្ចុប្បន្ននេះ ត្រូវបានកម្ពុជាផ្តល់សច្ចាប័ន និង បានតំកល់នៅក្នុងរដ្ឋធម្មនុញ្ញ ។ សេចក្តីសំរេចនាពេលថ្មីៗនេះ របស់ក្រុមប្រឹក្សាធម្មនុញ្ញបានបញ្ជាក់យ៉ាងច្បាស់ថា សន្ធិសញ្ញាទាំងនេះ គឺជាផ្នែកមួយនៃច្បាប់កំពូល ហើយថា ច្បាប់ ឬការអនុវត្តន៍ផ្សេងៗដែលរំលោភលើសន្ធិសញ្ញាទាំងនេះ ត្រូវទុកជានិរាករណ៍ ។

៣- ការបង្កើត និងការប្រព្រឹត្តទៅរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក៏ជាមានសារៈសំខាន់បំផុតផងដែរសំរាប់ប្រទេសនេះ ក្នុងការគោរពសិទ្ធិមនុស្ស ។ ការកាត់សេចក្តីនៅថ្ងៃខាងមុខនេះ បញ្ជាក់ថា គ្មានជនណាម្នាក់ស្ថិតនៅពីលើច្បាប់បានឡើយ ទោះជាជននោះមានឋានៈខ្ពស់ និងមានអំណាចខ្លាំងប៉ុនណាក៏ដោយ ។ មិនអាចមាននិទណ្ឌភាពរួចផុតពីការទទួលខុសត្រូវ និងការផ្តន្ទាទោសចំពោះការរំលោភឡើយ ផ្អែកលើបទដ្ឋានខ្ពស់បំផុតនៃយុត្តិធម៌ព្រហ្មទណ្ឌ ដែលជាសេចក្តីប្រាថ្នានៃបទដ្ឋានសិទ្ធិមនុស្ស ។ មានការសង្ឃឹមយ៉ាងមុតមាំថា ការងាររបស់សាលាក្តីនេះ មិនត្រឹមតែនាំទៅរកការចាប់ឱ្យទទួលខុសត្រូវចំពោះអំពើសាហាវយង់ឃ្នងបំផុតនៃរបបខ្មែរក្រហមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងនាំទៅរកភាពល្អប្រសើរឡើងជាទូទៅ ក្នុងការគ្រប់គ្រងប្រព័ន្ធយុត្តិធម៌នៅម្ពុជា ។ ការបង្កើតសាលាក្តី តាមរយៈការចូលរួមយ៉ាងសកម្មបំផុតពីសហគមន៍អន្តរជាតិ បង្ហាញថា យើងទាំងអស់គ្នាមានសម្បជញ្ញៈទទួលខុសត្រូវចំពោះការរំលោភសិទ្ធិមនុស្ស កាលបើកើតមាន ។ ការតស៊ូរបស់មនុស្សម្នាក់ៗដើម្បីសិទ្ធិមនុស្សក៏ជាការតស៊ូរបស់យើងទាំងអស់គ្នាដែរ ។ នៅពេលដែលយើងផ្តន្ទាទោសជនទាំងឡាយដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មក្នុងអតីតកាល យើងក៏មិនត្រូវបិទភ្នែក មិនអើពើចំពោះអំពើរំលោភសិទ្ធិមនុស្សដែលកំពុងកើតមានជារៀងរាល់ថ្ងៃដែរ ។ បច្ចុប្បន្ននេះ ការចេញមុខក្នុងការកាត់សេចក្តីនេះ បង្ហាញថា សហគមន៍អន្តរជាតិកំពុងបំពេញការទទួលខុសត្រូវបច្ចុប្បន្នរបស់ខ្លួន។ ឬក៏ ដោយសារនៅអតីតកាល សហគមន៍អន្តរជាតិរង់ចាំជាច្រើនទសវត្សមុនពេលដែលខ្លួនស្វែងរកការទទួលខុសត្រូវ និងយុត្តិធម៌សំរាប់ការរំលោភបំពានទាំងនេះ ? ។

៤- មានការសង្ឃឹមផងដែរថា ទន្ទឹមនឹងប្រជាពលរដ្ឋសង្កេតមើលការកាត់សេចក្តី ដែលលាតត្រដាងអំពីអំពើព្រៃផ្សៃសាហាវយង់ឃ្នងបំផុតទាំងនេះ ក៏នឹងមានការប្តេជ្ញាចិត្តជាថ្មីរបស់រដ្ឋាភិបាលចំពោះសិទ្ធិមនុស្សដែរ ។ តាមបទពិសោធនៅកម្ពុជា ក៏ដូចជានៅឆាកអន្តរជាតិ បង្ហាញឱ្យឃើញថា សូម្បីតែបន្ទាប់ពីមានសេចក្តីប្រកាសជាសកលនេះ ប្រព័ន្ធសន្ធិសញ្ញាអន្តរជាតិនានា និងប្រកាសរដ្ឋធម្មនុញ្ញស្តីពីសិទ្ធិមនុស្សហើយក្តី ក៏នៅតែមានការរំលោភសិទ្ធិមនុស្សជាទូទៅដែរ ។ អំពើប្រល័យពូជសាសន៍ដោយខ្មែរក្រហមបានកើតមានតែក្នុងរយៈពេលប៉ុន្មានឆ្នាំប៉ុណ្ណោះ បន្ទាប់ពីសហគមន៍អន្តរជាតិបានប្រកាសអំពីសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងបានអនុម័តអនុសញ្ញាប្រឆាំងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ។ សេចក្តីប្រកាសជាសកលនេះបានបញ្ជាក់ថា នេះគឺជាគោលដៅដ៏ធំមួយនៃសេរីភាពរួចផុតពីភាពភ័យខ្លាច ។ ទោះជាដូច្នេះក្តី ភាពភ័យខ្លាចនៅតែមាន ការភ័យខ្លាចរបស់រដ្ឋមួយ

ការភ័យខ្លាច នគរបាល និងតុលាការ គឺជាការរៀបរបស់សហគមន៍ និងគ្រួសារជាច្រើននៅកម្ពុជា ក៏ដូចជាការរៀបរាប់របស់ប្រជាជននៅតំបន់ផ្សេងៗទៀតនៅលើពិភពលោកផងដែរ ។

៥- ដូច្នេះ អ្វីដែលជាមេរៀននោះគឺ ការតស៊ូដើម្បីសិទ្ធិមនុស្ស និងសេចក្ដីថ្លៃថ្នូរជាមនុស្សគឺគ្មានទីបញ្ចប់ ដូចដែលខ្ញុំបានឃើញយ៉ាងច្បាស់អំពីការឈឺចាប់ នៅពេលខ្ញុំបានជួបសហគមន៍ដីក្រហម និងសហគមន៍ភូមិ៧៨ ។ អ្នកការពារសិទ្ធិមនុស្សខ្លាំងជាងគេបំផុតនោះមិនមែននគរបាល តុលាការ ឬ រដ្ឋាភិបាលទេ ។ ប្រជាពលរដ្ឋដែលត្រូវគេគំរាមបណ្ដេញចេញពីដីក្រហម បានរំលឹកប្រាប់ខ្ញុំថា រដ្ឋសភាស្ថិតនៅចំងាយតែប៉ុន្មានម៉ែត្រប៉ុណ្ណោះពីសហគមន៍នោះ ហើយបែបជាមិនអើពើចំពោះការឈឺចាប់របស់ប្រជាពលរដ្ឋ ។ អ្នកការពារសិទ្ធិមនុស្ស និងយុត្តិធម៌សង្គមខ្លាំងជាងគេបំផុតនោះ ត្រូវតែជាប្រជាពលរដ្ឋខ្លួនឯងផ្ទាល់តែម្ដង ដូចដែលពួកគាត់ត្រូវតែជាអ្នកការពារអធិបតេយ្យនយោបាយ និងសេដ្ឋកិច្ចរបស់កម្ពុជា ដូចបានប្រកាសនៅក្នុងរដ្ឋធម្មនុញ្ញ ។ សំរាប់ខ្លួនខ្ញុំផ្ទាល់ នេះគឺជាសារលិខិតមួយដ៏សំខាន់បំផុតនៅក្នុងទិវាសិទ្ធិមនុស្សនេះ ។ ខ្ញុំមានឱកាសដ៏ថ្លៃថ្លាបំផុត សូមចែករំលែកជាមួយអ្នកទាំងអស់គ្នានៅក្នុងទិវានេះ ។

End.